# កាឡាទី ៣:១៥-២៥

**ការរំលឹក** នៅក្នុងកាឡាទី ៣:១-១៤ យើងរៀនថា បញ្ហានៃពួកកាឡាទីគឺជាបញ្ហាដែលកើតឡើងជាច្រើនដងក្នុងសព្វថ្ងៃនេះផងដែរ។ គ្រីស្ទបរិស័ទចាប់ផ្តើមជីវិតនៅក្នុងព្រះគ្រីស្ទដោយគេជឿដំណឹងល្អ ប៉ុន្តែក្រោយមក គេចង់បន្តជីវិតនៅក្នុងព្រះគ្រីស្ទដោយប្រព្រឹត្តតាមក្រឹត្យវិន័យហើយគិតថា ព្រះជាម្ចាស់នឹងសង្គ្រោះគេដោយសារគេបានប្រព្រឹត្តតាមក្រឹត្យវិន័យ។ ប៉ុន្តែមិនមែនជាអស់អ្នកដែលកាត់ស្បែក (ឬប្រព្រឹត្តតាមក្រិត្យវិន័យ) ដែលទទួលព្រះពររួមជាមួយអ័ប្រាហាំនោះទេ ប៉ុន្តែអស់អ្នកដែលជឿដំណឹងល្អរបស់ព្រះគ្រីស្ទវិញ។ អស់អ្នកដែលពឹងផ្អែកលើការប្រព្រឹត្តតាមក្រឹត្យវិន័យត្រូវបណ្តាសា ប៉ុន្តែព្រះជាម្ចាស់បានរាប់យើងជាសុចរិតដោយយើងជឿលើព្រះគ្រីស្ទ។
សូមអានកាឡាទី ៣:១៥-២៥ ទាំងមូល។
សូមអានខ.១៥ ឡើងវិញ។ *តើមនុស្សអាចលើកចោល ឬ បន្ថែមបញ្ចូល «សេចក្តីសញ្ញា» របស់មនុស្សបានទេ?*

**ការពន្យល់** ពាក្យភាសាក្រិកនៅក្នុងខ.១៥ ដែលត្រូវបានបកប្រែ «សេចក្តីសញ្ញា» (នៅក្នុងព្រះគម្ពីរខ្មែរបរិសុទ្ធ) គឺជាពាក្យដែលអាចមានន័យថា «ការតាំងសញ្ញា» (គខប សម្ព័ន្ធមេត្រី) ឬអាចមានន័យថា «ពាក្យបណ្តាំ» (ដូច្នេះហើយ គម្ពីរ គខប បានបកប្រែពាក្យភាសាក្រិកដោយប្រើពាក្យ «ពាក្យបណ្តាំ»)។ បើមានមនុស្សម្នាក់បានសរសេរពាក្យបណ្តាំហើយស្លាប់ទៅ គ្មានអ្នកណាអាចផ្លាស់ប្តូរពាក្យបណ្តាំរបស់គាត់បានទេ។ មនុស្សចាំបាច់ត្រូវធ្វើតាមពាក្យបណ្តាំនោះ។ ពូជរបស់គាត់នឹងទទួលមរតកតាមពាក្យបណ្តាំរបស់គាត់។ នៅអត្ថបទនេះ លោកប៉ុលលើកយកឧទាហរណ៍មួយនេះដើម្បីបង្ហាញថា ការតាំងសញ្ញា (សម្ពន្ធមេត្រី) ដែលព្រះអង្គបានចងជាមួយអ័ប្រាហាំពុំបានលុបបំបាត់ទេ។

សូមអាន ខ.១៦។ ព្រះជាម្ចាស់មានព្រះបន្ទូលសន្យាដល់នរណា? ____________ និង ________________។

សូមអាន ខ.១៧។ *តើ ក្រឹត្យវិន័យបានលុបបំបាត់ពាក្យបណ្តាំ (ការតាំងសញ្ញា សម្ព័ន្ធមេត្រី) របស់ព្រះអង្គជាមួយអ័ប្រាហាំឬ?*

ហេតុអ្វីមិនបាន? ពីព្រោះក្រិត្យវិន័យមកដល់បួនរយសាមសិបឆ្នាំក្រោយមកទៀត ហើយលោកប៉ុលបានបង្ហាញហើយនៅខ.១៥ ថា គ្មាននរណាម្នាក់អាចលុបបំបាត់ ឬបន្ថែមបន្ថយពាក្យបណ្តាំរបស់មនុស្សបានទេ។

សូមអាន ខ.១៨។ *បើសិនជាមរដកនោះបានមកដោយអាងលើក្រិត្យវិន័យនោះ តើបានអាងលើសេចក្តីសន្យាឬទេ?*

**ការពន្យល់** គ្រូក្លែងក្លាយបានបង្រៀនថា សាសន៍ដទៃដែលបានជឿលើព្រះយេស៊ូវត្រូវប្រព្រឹត្តតាមក្រិត្យវិន័យប្រយោជន៍ដើម្បីអោយគេបានសង្គ្រោះ។ ក្នុងអត្ថបទនេះលោកប៉ុលលើកយកឧទាហរណ៍មួយពីវប្បធម៌នៅ

សម័យនោះ (ឧទាហរណ៍ស្ដីអំពីពាក្យបណ្ដាំ) ដើម្បីបង្ហាញថា ការបង្រៀនរបស់ពួកគេខុសឆ្គង។ ក្រិត្យវិន័យបានមកដល់បួនរយសាមសិបឆ្នាំក្រោយសម្ព័ន្ធមេត្រីជាមួយនឹងអ័ប្រាហាំ ដូច្នេះមិនបានលុបបំបាត់ពាក្យសន្យានោះទេ។ ដូច្នេះ យើងបានទទួលមរដក (យើងបានសង្គ្រោះ) ដោយព្រះគុណ គឺដោយសេចក្ដីសន្យា មិនមែនដោយប្រព្រឹត្តតាមក្រិត្យវិន័យឡើយ។ ម្ដងទៀត នេះបង្ហាញថា ជំនឿគ្រីស្ទបរិស័ទខុសប្លែកពីសាសនាផ្សេងៗទៀតដែលស្វែងរកសេចក្ដីសង្គ្រោះតាមរយៈការប្រព្រឹត្តរបស់ខ្លួន។

សូមអាន ខ.១៩-២០។ *ក្រឹត្យវិន័យកើតមានមកដើម្បីអ្វី?*

*ក្រិត្យវិន័យមានប្រយោជន៍នេះទាល់តែពេលណា?*

**ការពន្យល់** លោកប៉ុលបង្រៀនថា ក្រិត្យវិន័យមានប្រយោជន៍នៅក្នុងផែនការរបស់ព្រះជាម្ចាស់។ ក្រិត្យវិន័យបានមកក្រោយពីអ័ប្រាហាំ ប៉ុន្តែនៅមុនពូជពង្សរបស់អ័ប្រាហាំដែលត្រូវទទួល មរដកយាងមកដល់។
សូមអាន ខ.២១-២២។ *តើ ក្រឹត្យវិន័យអាចផ្ដល់ជីវិតឬទេ?*
*តើ មនុស្សនឹងបានសុចរិតដោយសារក្រឹត្យវិន័យឬទេ?*
*តើ នរណាបានទទួលផល ស្របតាមព្រះបន្ទូលសន្យា?*

សូមអាន ខ.២៣-២៥។ *តើ ក្រិត្យវិន័យធ្វើជាអ្នកដឹកនាំយើងរាល់គ្នាទៅដល់នរណា?*
*តើ យើងនៅក្រោមអំណាចរបស់អ្នកដឹកនាំ (ក្រិត្យវិន័យ) ឬទេ? ហេតុអ្វី?*

**ការពន្យល់** នៅទីនេះលោកប៉ុលបង្រៀនថា ក្រិត្យវិន័យមិនជាបញ្ហាទេ ប៉ុន្តែបញ្ហាមកពីមនុស្ស ពីព្រោះមនុស្សទាំងអស់នៅក្រោមអំណាចបាប។ ក្រិត្យវិន័យបានសំដែងអោយយើងឃើញបាបរបស់ខ្លួន ដូច្នេះវាបាននាំឲ្យយើងឃើញថា យើងត្រូវសំអាងទៅលើព្រះគ្រីស្ទ។ ដោយព្រោះយើងមានបាប មានតែម៉្យាងគត់ដែលយើងបានទទួលផលស្របតាមព្រះបន្ទូលសន្យាគឺ ជឿ *លើព្រះយេស៊ូវ* (មិនគ្រាន់តែជឿព្រះ)។ នៅពេលយើងដល់ព្រះគ្រីស្ទហើយ យើងមិននៅក្រោមអំណាចរបស់អ្នកដឹកនាំនោះទៀតទេ។
**ការអនុវត្ត** នៅពេលយើងរៀននិងបង្រៀនក្រិត្យវិន័យ យើងត្រូវយល់ឲ្យច្បាស់ថា តួនាទីរបស់ក្រិត្យវិន័យគឺ សំដែងអំពើបាបរបស់យើងនិងនាំយើងទៅដល់ព្រះគ្រីស្ទ។ ជាញឹកញាប់គ្រីស្ទបរិស័ទគិតថា គេបានទទួលពរឬសេចក្ដីសង្គ្រោះដោយគេស្ដាប់តាមក្រិត្យវិន័យ ប៉ុន្តែលោកប៉ុលបានថា «អស់អ្នកដែលអាងដល់ការប្រព្រឹត្តតាមក្រិត្យវិន័យនោះត្រូវបណ្ដាសាវិញ» (៣:១០)។ *តើអ្នកឬសមាជិកនៅក្នុងពួកជំនុំរបស់អ្នកអាងដល់ការប្រព្រឹត្តតាមក្រិត្យវិន័យឬទេ?*

**រំលឹកឡើងវិញ** *តើយើងបានរៀនអ្វីចេញពីកាឡាទី ៣:១៥-២៥?*